ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

65
6

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី
លេខ: ៦៤
ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣
**សាលដីកា**
លេខ: ៥៣២ "ខ"
ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៣

**សាលដីកា**
**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅសាលសវនាការជាសាធារណៈ នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៣ ។

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

១-ឯកឧត្តម [redacted] ជាប្រធាន
២-លោកស្រី [redacted] ជាចៅក្រម
៣-លោក [redacted] ជាចៅក្រម
៤-លោក [redacted] ជាចៅក្រម
៥-លោក [redacted] ជាចៅក្រម

**ក្រឡាបញ្ជី**

លោកស្រី [redacted]

**តំណាងមហាអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញា

**ដើមចោទ:** ឈ្មោះ [redacted] ណារឿន ( ជាម្ចាស់បណ្តឹងសាទុក្ខ ) ភេទប្រុស អាយុ៥៧ឆ្នាំ ជាតិខ្មែរ មុខរបរមន្ត្រីចូលនិវត្តន៍ មានទីលំនៅសព្វថ្ងៃផ្ទះលេខ ០៨E₀ ផ្លូវលំ ភូមិព្រៃព្រីងខាងជើង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

មានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ ។

**ចុងចម្លើយ:** ឈ្មោះ [redacted] ស្រីរ័ត្ន (ជាចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ២៨ឆ្នាំ ជាតិខ្មែរ មុខរបរកម្មករ មានទីលំនៅសព្វថ្ងៃផ្ទះលេខ ០៨E₀ ផ្លូវលំ ភូមិព្រៃព្រីងខាងជើង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។



មហាវិថី សម្តេចសុធារស, សង្កាត់ចតុមុខ, ខណ្ឌដូនពេញ, កម្ពុជា Sothearos Blvd, Sangkat Chatomuk, Khan Daun Penh, Cambodia

Scanned with CamScanner

**កម្មវត្ថុបណ្តឹង:**

-ឈប់រស់នៅជាអនីតិសង្វាស

-បែងចែកទ្រព្យសម្បត្តិរួម

-គ្រប់គ្រងទ្រព្យសម្បត្តិដោយឡែក

-គ្រប់គ្រងកូន ។

## អំពីអង្គហេតុ និង ចំណុចវិវាទ

### ក.អំពីអង្គហេតុ ជាមូលហេតុនៃការទាមទារ:

តាមពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ [redacted] ណារឿន ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១១ បានប្តឹងថា ខ្លួន និងឈ្មោះ [redacted] ស្រីរ័ត្ន បានរួមរស់នៅជាមួយគ្នាបែបអនីតិសង្វាស ជាប្តីប្រពន្ធលួចលាក់ ពុំបានរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ និងពុំមានសំបុត្រអាពាហ៍ពិពាហ៍ឡើយ ហើយការរួមរស់នៅជាមួយគ្នានេះ មិនបានប៉ុន្មាន គឺនៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៧ ក៏មានការទាស់ទែងគ្នា និងលែងលះគ្នាម្តងរួចមកហើយ ដោយឈ្មោះ [redacted] ស្រីរ័ត្ន នេះបានទាមទារជាថ្នូរនូវទឹកប្រាក់ចំនួន ២.០០០ដុល្លា (ពីរពាន់ដុល្លារអាមេរិក) ដោយសន្យានឹងឈប់រួមរស់ជាមួយគ្នាទៀតហើយ ។ ដូចមានកិច្ចសន្យាយល់ព្រមលែងលះ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៧ ។ តែក្រោយមករយៈពេលមួយខែ ឈ្មោះ [redacted] ស្រីរ័ត្ន នេះបានប្រឡប់មកសុំរួមរស់នៅជាមួយខ្ញុំបាទជាប្តីម្តងទៀត ដោយសន្យាថា នឹងឈប់ប្រព្រឹត្តអំពើអបាយមុខផ្សេងៗ ដូចជា ដើរលេងល្បែងស៊ីសង ប្រព្រឹត្តអំពើអ្វីៗតាមតែចិត្តខ្លួនឯង នឹងមានអត្តចរិតរឹងរូសមិនស្តាប់បង្គាប់ប្តីជាដើម ។ ឃើញដូច្នេះ ខ្ញុំបាទក៏បានយល់ព្រមឲ្យឈ្មោះ [redacted] ស្រីរ័ត្ន រស់នៅជាមួយខ្ញុំបាទម្តងទៀត ក្រែងឈ្មោះនេះ មានការកែប្រែអត្តចរិតថ្មី ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៩៥(យ) ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ទទួលស្គាល់ការសុំឈប់រស់នៅលក្ខណៈជាប្តីប្រពន្ធបែបអនីតិសង្វាសរវាងឈ្មោះ [redacted] ណារឿន ភេទប្រុស អាយុ៥៧ឆ្នាំ និងឈ្មោះ [redacted] ស្រីរ័ត្ន ភេទស្រី អាយុ២៨ឆ្នាំ ចាប់ពីពេលនេះតទៅ តាមការព្រមព្រៀងរបស់គូភាគី ។

២-ប្រគល់កូនពីរនាក់ គឺឈ្មោះ [redacted] រ័ត្នដានូ ភេទស្រី កើតថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៥ និងឈ្មោះ [redacted] រ័ត្នដាណា ភេទស្រី កើតថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៩ ឲ្យភាគីចុងចម្លើយឈ្មោះ ចាន់ ស្រីរ័ត្ន ជាម្តាយទទួលសិទ្ធិគ្រប់គ្រង ចិញ្ចឹម បីបាច់ថែរក្សា មើលការខុសត្រូវ អប់រំឲ្យរៀនសូត្រមានអនាគតល្អ ដោយឲ្យដើមចោទឈ្មោះ [redacted] ណារឿន ជាឪពុកជួយចេញអាហារកិច្ចចិញ្ចឹមកូនៗពីរនាក់ចំនួន ១០០.០០០រៀល (ដប់ម៉ឺនរៀល) ក្នុងមួយខែឲ្យចុងចម្លើយ គិតចាប់ពីថ្ងៃប្រកាសសាលក្រម គឺថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១២ រហូតដល់កូនៗមាននីតិភាព ។

៣-ឲ្យភាគីចុងចម្លើយជាអ្នកមានអំណាចមេបាលើកូន បង្កលក្ខណៈងាយស្រួលគ្រប់



Scanned with CamScanner

65
4

បែបយ៉ាងដល់ភាគីដើមចោទជាឪពុកមានលទ្ធភាពគ្រប់គ្រាន់ទៅមកសាកសួរសុខទុក្ខកូនៗ គ្រប់ពេលវេលា ។

៤-អំពីទ្រព្យសម្បត្តិរួមមាន:

ក/-ទ្រព្យសម្បត្តិកម្មសិទ្ធិដោយឡែករបស់ដើមចោទឈ្មោះ [redacted] ណារឿន គឺផ្ទះលេខ ០៨E₀ ផ្លូវលំ ភូមិព្រៃព្រីងខាងជើង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ តាមលិខិតផ្ទេរសិទ្ធិកាន់កាប់ដី-ផ្ទះលេខ ១៥១១ បជ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០៩ ត្រូវប្រគល់ឲ្យដើមចោទទទួលសិទ្ធិកាន់កាប់គ្រប់គ្រងជាម្ចាស់កម្មសិទ្ធិតាមច្បាប់តទៅ ។

ខ/-ដីស្រែទំហំ ២០១៦ម៉ែត្រការ៉េ ស្ថិតនៅភូមិត្រាវអែម ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ ម្ចាស់កម្មសិទ្ធិឈ្មោះ [redacted] ណារឿន និងឈ្មោះ [redacted] ស្រីវត្ត តាមលិខិតបញ្ជាក់សុំកាន់កាប់ ប្រើប្រាស់ដីធ្លីលេខ ៤៣០/០៩ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៩ របស់ប្រធានឃុំពពេល ត្រូវប្រគល់ឲ្យភាគីចុងចម្លើយឈ្មោះ [redacted] ស្រីវត្ត ទទួលសិទ្ធិកាន់កាប់គ្រប់គ្រងជាម្ចាស់កម្មសិទ្ធិតាមច្បាប់តទៅ ។

-ដីស្រែប្រវែងបណ្តោយ ៥១,៥០ម និងទទឹងប្រវែង ៤៣ម (២២១៤ម៉ែត្រការ៉េ) ស្ថិតនៅភូមិត្រាវអែម ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានម្ចាស់កម្មសិទ្ធិឈ្មោះ [redacted] ណារឿន និងឈ្មោះ [redacted] ស្រីវត្ត តាមលិខិតទិញ និងលក់ដីលេខ ០៧៧/១០ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១០ របស់មេឃុំពពេល គឺត្រូវបែងចែកជាពីរចំណែកស្មើៗគ្នា រវាងគូភាគី ។

ការប្តឹងទាមទារបែងចែកទ្រព្យសម្បត្តិរួមក្រៅពីចំណុចដូចខាងលើ គ្មានភស្តុតាងបញ្ជាក់តុលាការមិនលើកមកពិចារណា និងសម្រេចទេ ។

៥-សាលក្រមនេះ បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១២ ចំពោះមុខដើមចោទ និងចុងចម្លើយ ព្រមទាំងមេធាវីតំណាងដោយអាណត្តិ និងប្រកាសជាសាធារណ:នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១២ ចំពោះមុខដើមចោទ និងចុងចម្លើយ ព្រមទាំងមេធាវីតំណាងដោយអាណត្តិ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ២៦០ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១២ របស់ឈ្មោះ ចាន់ ស្រីវត្ត ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ៤៥(យ) ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទី២ ,ទី៤ និងទី៥ នៃសេចក្តីសម្រេច

បានឃើញសាលដីការដ្ឋប្បវេណីលេខ ០៧(ក្រ IV អ) ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ច្រានចោលបណ្តឹងឧទ្ធរណ៍លេខ ២៦០ ចុះថ្ងៃទី២៧-៨-២០១២ របស់ឈ្មោះ [redacted] ស្រីវត្ត ត្រង់ចំណុចទី២ នៃសេចក្តីសម្រេច ។

២-តម្កល់ចំណុចទី២ នៃសាលក្រមលេខ ៤៥(យ) ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ។



Scanned with CamScanner

65
3

៣-លុបចោលចំណុចទី៤-ក នៃសេចក្តីសម្រេចសាលក្រមលេខ ៤៥(ឃ) ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៤-បែងចែកជាពីរចំណែក ផ្ទះលេខ ០៨E₀ ផ្លូវលំ ភូមិព្រៃព្រីងខាងជើង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ តាមតម្លៃទីផ្សារឲ្យឈ្មោះ [redacted] ណារឿន មួយចំណែក និងឈ្មោះ [redacted] ស្រីរ័ត្ន មួយចំណែកស្មើគ្នា ។ ចំណុចផ្សេងទៀតនៃសាលក្រមតម្កល់ទុកជាបានការដដែល ។

៥-ប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់ដើមចោទ ។

៦-សាលដីកានេះបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសជាសាធារណៈ បើកសិទ្ធិប្តឹងសាទុក្ខរយៈពេល ១ខែ គិតពីថ្ងៃបានទទួលការបញ្ជូនសាលដីកានេះ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៧៩ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៣ របស់ឈ្មោះ [redacted] ណារឿន ប្តឹងមិនសុខនឹងសាលដីការដ្ឋប្បវេណីលេខ ០៧(ក្រ IV អ) ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទី៣ ,ទី៤ និងទី៥ នៃសេចក្តីសម្រេច ។

**ខ.អំពីសេចក្តីថ្លែងការណ៍របស់គូភាគី:**

ឈ្មោះ [redacted] **ណារឿន** -ជាម្ចាស់បណ្តឹងសាទុក្ខ បានធ្វើសេចក្តីថ្លែងការណ៍នាពេលសវនាការថា: ខ្លួនមិនសុខចិត្តនឹងការសម្រេចរបស់សាលាឧទ្ធរណ៍ នោះទេ ដោយសាលាឧទ្ធរណ៍ បានលុបចោលនូវសាលក្រមសាលាដំបូងរាជធានីភ្នំពេញ ដែលបានសម្រេចឲ្យទ្រព្យដែលជារបស់ខ្លួនមកខ្លួនហើយ ព្រោះខ្លួនមានសំអាងហេតុផ្លូវច្បាប់ត្រឹមត្រូវ និងក៏ជាទ្រព្យដែលខ្លួនខិតខំប្រឹងប្រែងដោយខ្លួនឯង ក្រោយពេលដែលខ្លួនបានព្រមព្រៀងបែកគ្នាកាលពីឆ្នាំ២០០៧ មក ដោយឈ្មោះ [redacted] ស្រីរ័ត្ន បានយល់ព្រមទទួលយកប្រាក់អាហារកិច្ច ២.០០០$ ដែលមានម្តាយរបស់ [redacted] ស្រីរ័ត្ន យល់ព្រមផងដែរ ។ ចំណែកផ្ទះនេះ ខ្លួនបានទិញនៅឆ្នាំ២០០៩ ហើយមិនបានដាក់ឈ្មោះ [redacted] ស្រីរ័ត្ន នោះទេ ។

__សំណូមពរ:__ សុំទាមទារយកផ្ទះល្វែងរបស់ខ្លួនវិញ ។

លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ [redacted] **ណារឿន** បានធ្វើសេចក្តីសន្និដ្ឋាននាពេលសវនាការថា: កូនក្តីខ្ញុំមិនមានសំបុត្រអាពាហ៍ពិពាហ៍ ហេតុនេះមិនមានអានុភាពតាមច្បាប់អាពាហ៍ពិពាហ៍ទេ ហើយផ្ទះល្វែងនោះ ក៏ជាទ្រព្យដោយឡែករបស់កូនក្តីខ្ញុំដែរ ព្រោះបានចុះបញ្ជីឈ្មោះតែកូនក្តីខ្ញុំម្នាក់ ។

មកដល់ពេលនេះ កូនក្តីខ្ញុំសាទុក្ខលើតែផ្ទះល្វែងលេខ ០៨E₀ ផ្លូវលំ ភូមិព្រៃព្រីងខាងជើង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ប៉ុណ្ណោះ ។

__សំណូមពរ:__ សុំពិចារណាលើសាលដីកាសាលាឧទ្ធរណ៍ និងបង្វិលសំណុំរឿងនេះ ទៅសាលាឧទ្ធរណ៍ ដើម្បីសម្រេចជាថ្មីឡើងវិញ ។



៣៥៣

353

-ក្រោយពីស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់ដើមចោទ និងមេធាវីរបស់ដើមចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការកំពូល**

-យល់ឃើញថា: បណ្តឹងសាទុក្ខលេខ ៧៩ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៣ របស់ដើមចោទ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី និងមាត្រា ២៨៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

-យល់ឃើញថា:ដើមចោទមិនសុខចិត្តចំពោះការដែលសាលាឧទ្ធរណ៍សម្រេចបែងចែកផ្ទះល្វែងលេខ ០៨E₀ ជាពីរចំណែកស្មើគ្នា ដូច្នេះ តុលាការកំពូលពិចារណាតែចំណុចនេះ ។

-យល់ឃើញថា: ដើមចោទបានទិញផ្ទះនេះតាមលិខិតផ្ទេរសិទ្ធិកាន់កាប់ដី និងផ្ទះលេខ ១៥១១ បជ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០៩ ដែលមានឈ្មោះ [redacted] ណារឿន តែម្នាក់ឯង ហេតុនេះ ក្នុងករណីដែលអ្នកទាំងពីររស់នៅជាអនីតិសង្វាស បើអ្នកទាំងពីរបញ្ចប់ស្ថានភាពនេះ សហាព័ទ្ធម្នាក់ៗត្រូវយកទ្រព្យសម្បត្តិរបស់ខ្លួនរៀងៗខ្លួន ។ ដី និងផ្ទះទំនាស់នេះ ដែលមានឈ្មោះដើមចោទតែម្នាក់ ក៏តុលាការមិនអាចតម្រូវឲ្យបែងចែកគ្នាបានដែរ ដរាបណាម្ចាស់ទ្រព្យមិនយល់ព្រម ដូច្នេះ ការដែលសាលាឧទ្ធរណ៍ សម្រេចឲ្យចែកអចលនវត្ថុនេះ គឺជាការមិនត្រឹមត្រូវទេ ពីព្រោះគូភាគីមិនបានបំពេញកិច្ចស្របតាមមាត្រា ១៤ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ។

-យល់ឃើញថា: ចុងបណ្តឹងសាទុក្ខបានទទួលដីកាកោះហើយ តែមិនបានចូលរួមទេ ដោយម្តាយបានដាក់ពាក្យសុំពន្យាពេល ដោយសំអាងហេតុថា ចុងបណ្តឹងសាទុក្ខមានជម្ងឺ នៅសំរាកពេទ្យ តែមិនមានជូនភស្តុតាងអ្វីអំពីការអះអាងនេះទេ ដូច្នេះតុលាការកំពូល មិនពិចារណាអំពីការសុំពន្យាពេលសវនាការនេះទេ ។

-យល់ឃើញថា:សាលដីការដ្ឋប្បវេណីលេខ ០៧(ក្រ IV អ) ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ មិនត្រឹមត្រូវនឹងគតិច្បាប់ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១-ទទួលបណ្តឹងសាទុក្ខលេខ ៧៩ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៣ របស់ដើមចោទ។

២-បដិសេធសាលដីការដ្ឋប្បវេណីលេខ ០៧(ក្រ IV អ) ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ លើចំណុចបែងចែកផ្ទះលេខ ០៨E0 ។



Scanned with CamScanner

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ៦៤ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ជំនុំជំរះជាថ្មី លើចំណុចដែលទាក់ទងនឹងផ្ទះលេខ០៨$E_0$ ។

៤-ប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់ចុងចម្លើយ ។

៥-សាលដីកានេះ ជំនុំជំរះ និងប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៣ ។

ឯកឧត្តម [redacted] ប្រធាន
លោកស្រី [redacted] ចៅក្រម
លោក [redacted] ចៅក្រម
លោក [redacted] ចៅក្រម
លោក [redacted] ចៅក្រម
លោកស្រី [redacted] ក្រឡាបញ្ជី

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មករា ឆ្នាំ២០១៤
ក្រឡាបញ្ជី
[redacted]

បានឃើញ
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មករា ឆ្នាំ២០១៤
ប្រធាន
[redacted]